ព្រះយេស៊ូវគ្រីស្ទទ្រង់បានសុគតនៅលើឈើឆ្កាង ជំនួសបាបរបស់មនុស្សទាំងអស់ ហើយទ្រង់ត្រូវបានគេបញ្ចុះនៅក្នុងផ្នូរអស់រយៈពេល៣ថ្ងៃ ៣យប់ ទ្រង់ក៏រស់ពីសុគតឡើងវិញ ហើយយើងត្រូវទទួលថ្លែងប្រាប់ថា ទ្រង់គឺជាព្រះពិតតែ១ពិតប្រាកដមែន ។

ខិតប័ណ្ណនេះគ្រាន់តែជួយណែនាំបងប្អូន ឱ្យដឹងនូវការដែលព្រះយេស៊ូវគ្រីស្ទចង់សង្គ្រោះមនុស្សប៉ុណ្ណោះហើយ បើបងប្អូនជឿ ក៏សំរេចនៅលើចិត្តរបស់បងប្អូន តែបើមិនជឿនោះស្រេចតែចិត្តរបស់បងប្អូនដែរ នេះយើងមិនបង្ខំឱ្យបងប្អូនទាំងអស់គ្នាទទួលជឿព្រះយេស៊ូវគ្រីស្ទទេ ក៏ប៉ុន្តែយើងគ្រាន់តែចង់ឱ្យបងប្អូនពិចារណាគិតថា តើបងប្អូនត្រូវធ្វើអ្វី ដើម្បីឱ្យបានសង្គ្រោះចេញពីអំពើបាប បើបងប្អូនសំរេចចិត្តថា ចង់អំពាវនាវដល់ព្រះយេស៊ូវគ្រីស្ទនោះ ចូរអំពាវនាវដូចខាងក្រោមនេះ

*ឱព្រះអម្ចាស់អើយ ខ្ញុំដឹងថា ខ្លួនមានបាប ហើយសមនឹងទទួលទោសនៅឋាននរក អស់កល្បជានិច្ច ប៉ុន្តែខ្ញុំជឿថាព្រះយេស៊ូវគ្រីស្ទស្រឡាញ់ខ្ញុំ ហើយបានសុគតជំនួសខ្ញុំ និងបានរស់ពីស្លាប់ឡើងវិញផង ដូច្នេះខ្ញុំសូមឱ្យព្រះអង្គមេត្តាអត់ទោសអំពើបាបរបស់ខ្ញុំហើយសូមជួយសង្គ្រោះខ្ញុំពីឋាននរក សូមឱ្យព្រលឹងវិញ្ញាណខ្ញុំទៅស្ថានសួគ៌នៅពេលណាដែលខ្ញុំស្លាប់ សូមអរព្រះគុណដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដោយព្រោះទ្រង់បានសង្គ្រោះខ្ញុំហើយ អាម៉ែន ។*

បើអ្នកទើបទទួលព្រះអង្គដោយចិត្តជឿ សូមជូនដំណឹងឱ្យពួកយើងនៅអាស័យដ្ឋានខាងក្រោមនេះ៖

ការិយាល័យ សំរាប់ទាក់ទង
ប្រអប់ ប្រៃសណីយ៍ ២៥០៦
ភ្នំពេញ ៣

# តើអ្វីដែល សំខាន់ ជាងគេបំផុត?







## តើអ្វីដែលសំខាន់ជាងគេបំផុត នៅក្នុងជីវិតរបស់អ្នក ?

មានមនុស្សជាច្រើនគេគិតថា អ្វីៗដែលសំខាន់ជាងគេបំផុតសំរាប់ជីវិតរបស់គេ គឺមាស ប្រាក់ពេជ្រត្បូងឡាន ស្អាតៗផ្ទះធំៗ ដែលមានតំលៃ ហើយគេក៏និយាយថា របស់ទាំងនោះគឺមានតំលៃខ្លាំងណាស់ លើសជាងជីវិតរបស់គេទៅទៀត ។ ក៏ប៉ុន្តែគេភ្លេចគិតថា ប្រសិនបើគេមានទ្រព្យសម្បត្តិពេញលោកីយទាំងមូលក៏ដោយ តែបើគេបាត់ជីវិតទៅ តើមានប្រយោជន៏អ្វីសំរាប់គេ ? ដូច្នេះហើយ ទើបយើងនិយាយថា គេបានភ្លេចគិតថានៅមានរបស់ម្យ៉ាង ដែលមានតំលៃ ច្រើនជាងរបស់ទាំងនោះទៅទៀត គឺជា **ជីវិតអស់កល្បជានិច្ច** ដែលមានន័យថា មិនចេះស្លាប់ខាងព្រលឹងវិញ្ញាណមិនមែនរូបកាយទេ ពីព្រោះរូបកាយខាងសាច់ឈាមរបស់មនុស្សទាំងអស់នឹងត្រូវស្លាប់ គ្មានអ្នកណាអាចរស់បានរហូតឡើយ សូម្បីតែគេមានអាយុច្រើនយ៉ាងណាក៏ដោយ គង់តែគេនៅតែស្លាប់ដដែល ។ ដោយហេតុនេះហើយយើងត្រូវដឹងថា បើមនុស្សគ្មានជីវិតអស់កល្បជានិច្ច តើមានប្រយោជន៏អ្វី ? ព្រោះនៅក្នុងព្រះគម្ពីរម៉ាកុស ៨:៣៦ ថា " ដ្បិតបើមនុស្សណានិងបានលោកីយ ទាំងមូលតែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៏អ្វីដល់អ្នកនោះ ដូច្នេះយើងត្រូវតែស្វែងរកព្រះជាមុនសិន ពីព្រោះនៅក្នុងព្រះគម្ពីរម៉ាថាយ ៦:៣៣ និយាយថា" ចូរស្វែងរកនគរ នឹងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះនឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង ។ ហើយក៏មានមនុស្សជាច្រើនបានសួរថា បើយើងស្វែងរកព្រះយើងបានប្រយោជន៏អ្វី ?បើយើងចង់ស្វែងរកព្រះ បានដោយរបៀបណា? ប្រហែលជាបងប្អូនក៏ឆ្ងល់ដូចជាពួកគេដែរ ចំលើយសំរាប់សំនួរនេះ មាននៅក្នុងព្រះគម្ពីរយ៉ូហាន ១៧:៣ "នេះជាជីវិតដ៏នៅអស់កល្បជានិច្ច គឺឱ្យគេបានស្គាល់ដល់ទ្រង់ ដ៏ជាព្រះពិតតែ១ នឹងព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានចាត់ឱ្យមកផង" ដូច្នេះនៅពេលដែលយើងស្គាល់ព្រះ នោះយើងនឹងទទួលបានផលប្រយោជន៏ដ៏មានតំលៃ ថ្លៃលើសអ្វីៗទាំងអស់ គឺយើងនឹងមាន**ជីវិតដ៏នៅអស់កល្បជានិច្ច** នៅជាមួយនឹង**ព្រះនៅស្ថានសួគ៌អស់កល្បជានិច្ចដែរ**។ ក៏ប៉ុន្តែមនុស្សទាំងអស់បានធ្វើបាបហើយ ពីព្រោះនៅក្នុងព្រះគម្ពីរ រ៉ូម ៣:២៣ ថា"ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ " ដូច្នេះយើងទាំងអស់គ្នាជាមនុស្សដែលមានបាប ដោយហេតុនេះហើយយើងត្រូវតែសារភាពបាបរបស់យើងទាំងប៉ុន្មាន ដើម្បីសូមឱ្យព្រះជួយអត់ទោសអំពើបាបរបស់យើង ព្រោះយើងមិនអាចលាងអំពើបាបដោយខ្លួនឯងបានទេ ។ ឧទាហរណ៍ មានក្មេងម្នាក់បានធ្លាក់ទៅក្នុងលូទឹកស្អុយ ហើយបានប្រលាក់ខ្លួនទាំងអស់ដោយទឹកស្អុយ ចំណែកឪពុករបស់ក្មេងនោះ គាត់ស្អប់ទឹកស្អុយណាស់ ព្រោះវាគួរឱ្យខ្ពើមណាស់នៅចំពោះគាត់ ដូច្នេះតើគាត់ត្រូវតែស្អប់កូន ដោយព្រោះទឹកស្អុយអីរអឺទេគាត់មិនស្អប់កូនទេ គឺគាត់ស្អប់តែទឹកស្អុយប៉ុណ្ណោះ ព្រោះគាត់មិនចង់ចោលកូនទេ តែចង់ចោលទឹកស្អុយវិញ ចំណែកឯព្រះវិញ ក៏យ៉ាងដូច្នេះដែរ ទ្រង់មិនស្អប់មនុស្ស ដោយព្រោះមនុស្សបានប្រលាក់ខ្លួន ដោយអំពើបាបនោះទេ ហើយព្រះក៏មិនចង់ចោលមនុស្សដែរ តែទ្រង់ចង់លាងអំពើបាបចេញពីមនុស្សវិញ ដើម្បីឱ្យមនុស្សបានញែកចេញជាបរិសុទ្ធនៅចំពោះព្រះ ។ ដោយហេតុនេះហើយយើងត្រូវដឹងថា យើងមិនអាចសង្គ្រោះខ្លួនឯងបានទេ ដូច្នេះមានតែផ្លូវមួយប៉ុណ្ណោះ គឺអ្នកត្រូវតែអំពាវនាវរកព្រះ សូមឱ្យទ្រង់ជួយអត់ទោសបាបឱ្យអ្នក ដោយសារការដែលអ្នកសារភាពទោសកំហុសរបស់អ្នកដល់ព្រះ បើសូមឱ្យទ្រង់ជួយ នោះទ្រង់ប្រាកដជានឹងជួយដល់អ្នក ។ ពីព្រោះមានខគម្ពីរនៅក្នុងព្រះគម្ពីរ យ៉ូហានទី១ ១:៩ ថា "បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិតប្រយោជន៏នឹងអត់ទោសបាបឱ្យយើង ហើយនឹងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង ដូច្នេះ បើបងប្អូនចង់យាងព្រះយេស៊ូវគ្រីស្ទ ឱ្យទ្រង់យាងមកគង់នៅក្នុងខ្លួនរបស់បងប្អូន ហើយឱ្យទ្រង់សង្គ្រោះចេញពីអំពើបាប នោះយើងត្រូវតែជឿថា